# លក្ខន្តិកៈ

# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

HOUSING DEVELOPMENT ASSOCIATION OF CAMBODIA

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.

លក្ខន្តិកៈនេះកំណត់នូវការបង្កើត និងការគ្រប់គ្រងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## គោលបំណង

### ប្រការ ២. គោលបំណង

សមាគម **ស.អ.ល.ក** ត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចតទៅ៖

- ការពារសិទ្ធិស្របច្បាប់ និងសុចរិតភាពរបស់សមាជិកអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
- ចូលរួមសហការផ្តល់ព័ត៌មានជូនដល់រាជរដ្ឋាភិបាលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ នៃវិស័យសំណង់ទាំងអស់នៅកម្ពុជា
- ផ្តល់នូវឱកាសសម្រាប់ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងអ្នកអភិវឌ្ឍន៍លំនៅឋានដូចគ្នា និងអាជ្ញាធរពាក់ព័ន្ធ
- ចូលរួមសហការជាមួយរាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ នូវរាល់ការវិនិយោគដែលមានភាពមិនច្បាស់លាស់ ឬបង្កភាព ចលាចលដល់ទីផ្សារលំនៅឋាន
- ចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ និងរួមចំណែកជួយស្តារហេដ្ឋារចនាសម្ព័ន្ធនានា នៅប្រទេសកម្ពុជា។

## ជំពូកទី ៣

## នាមករណ៍ អត្តសញ្ញាណ អត្តិភាពគតិយុត្ត

### ប្រការ ៣.

- សមាគមនេះមានឈ្មោះជាផ្លូវការថា"**សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា** " ដែលមានអក្សរកាត់ " **ស.អ.ល.ក** "។
- ជាភាសាអង់គ្លេសថា: Housing Development Association of Cambodia (HDAC)។

### ប្រការ ៤. ស្លាកសញ្ញា

សមាគម **ស.អ.ល.ក** មានស្លាកសញ្ញាមានចែងក្នុងឧបសម្ព័ន្ធដូចជា:

- រូបរង្វង់មូលមានផ្ទៃជាយខាងក្រៅពណ៌ខៀវ និងពាក់កណ្តាលរង្វង់ខាងលើមាន អក្សរពណ៌សថា "សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា" និងពាក់កណ្តាលរង្វង់ខាងក្រោមមានអក្សរ "Housing Development Association of Cambodia" ជាតំណាង។
- រូបផ្ទះមានប្រអប់ដៃចាប់ដៃ នៅផ្នែកខាងក្នុងពណ៌ស ជាតំណាងឲ្យសហការប្រតិបត្តិផ្ទៃក្នុងរបស់សមាគម

ត្រារបស់សមាគម មានកងមូលពីរជាន់ដែលមានសណ្ឋានដូចនឹងរូបសញ្ញាមានទំហំ ៣៤មីលីម៉ែត្រ និងប្រើទឹកល័ក្តពណ៌ខៀវ។

### ប្រការ ៥. អត្តិភាពគតិយុត្ត

សមាគម **ស.អ.ល.ក** ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៥ នៅរាជធានីភ្នំពេញ ដោយមហាសន្និបាតពេញអង្គលើកទី១ ត្រូវបានប្រារព្ធធ្វើនៅសណ្ឋាគារកាំបូឌីយ៉ាណា។

### ប្រការ ៦. ទីស្នាក់ការ

សមាគម **ស.អ.ល.ក** មានទីស្នាក់ការនៅ រាជធានីភ្នំពេញ ។ ក្នុងករណីចាំបាច់សមាគមអាចផ្លាស់ប្តូរទីស្នាក់ការកណ្តាលបានតាមសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិ។

### ប្រការ ៧.អត្តសញ្ញាណ

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់ចំណេញ មិនធ្វើនយោបាយ មិនបម្រើឲ្យគណបក្សនយោបាយ។ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បម្រើឲ្យសមាជិកភាព និងផលប្រយោជន៍ជាសាធារណៈប៉ុណ្ណោះ ។

## ជំពូកទី ៤

## សមាជិក

### ប្រការ ៨. សមាជិក

សមាជិកសមាគម **ស.អ.ល.ក** ចែកចេញជា ៤ ប្រភេទ:

**ក. សមាជិកកិត្តិយសៈ** សំដៅដល់សមាជិកដែលធ្លាប់មានអតីតភាពជាប្រធាន ឬអនុប្រធានគណៈកម្មការប្រតិបត្តិដែលផុតអាណត្តិ និង/ឬ ឥស្សរៈជន និង/ឬ សប្បុរសជន ដែលបានធ្វើការបរិច្ចាគធនធានជាហិរញ្ញវត្ថុ ឬជាចំណេះដឹងដល់សមាគម និងត្រូវបានសម្រេចទទួលស្គាល់ដោយ គណៈកម្មការប្រតិបត្តិ។

**ខ. សមាជិកស្ថាបនិកៈ** សំដៅដល់អ្នកអភិវឌ្ឍន៍លំនៅឋានទាំងឡាយណាដែលបាន ចូលរួមយ៉ាងសកម្មក្នុងការផ្តួចផ្តើមគំនិត និងការរៀបចំបង្កើតសមាគមរហូតដល់មាន ស្ថិរភាព គតិយុត្ត។

**គ. សមាជិកសកម្មៈ** សំដៅដល់អ្នកអភិវឌ្ឍន៍លំនៅឋានទាំងឡាយណាដែលបានចូលរួមយ៉ាងសកម្មនូវរាល់សកម្មភាពរបស់សមាគម។

**ឃ. សមាជិកគាំទ្រៈ** សំដៅដល់សមាជិកទាំងឡាយណាដែលមានឆន្ទៈក្នុងការចូលរួម គាំទ្រជាមួយបុព្វហេតុរបស់សមាគមជាបន្តបន្ទាប់មក និងបានចូលរួមឧបត្ថម្ភដល់សមាគម ទោះបីរូបវន្តបុគ្គល ឬនីតិបុគ្គលនោះមិនមានធុរកិច្ចពាក់ព័ន្ធទៅនឹងអាជីវកម្មអភិវឌ្ឍន៍លំនៅឋានក៏ដោយ។ សមាជិកនេះគ្មានសិទ្ធិបោះឆ្នោតឈរឈ្មោះឲ្យគេបោះឆ្នោត ឬ សិទ្ធិសម្រេចនានាក្នុងគណៈកម្មាធិការប្រតិបត្តិឡើយ។

## ប្រការ ៩. សិទ្ធិ និង ភារកិច្ចរបស់សមាជិក

**ក. សិទ្ធិៈ** សមាជិកគ្រប់រូបមានសិទ្ធិដូចតទៅៈ

- បោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសរើសតាំងសម្រាប់តំណែងដឹកនាំសមាគមលើកលែងសមាជិកគាំទ្រ។ ការបោះឆ្នោតត្រូវអនុវត្តតាមគោលការណ៍ប្រជាធិបតេយ្យ និងប្រព្រឹត្តទៅ ដោយសេរី និងយុត្តិធម៌។

- ផ្តល់យោបល់ដើម្បីការរីកចម្រើនដល់សមាគម និងទទួលយកផលប្រយោជន៍តាមលក្ខណៈ វិនិច្ឆ័យនៃការកំណត់របស់សមាគមក្នុងការបំពេញភារកិច្ច ប្រសិនបើមានការលំបាក ឬ ជួបឧបសគ្គ សមាជិកគ្រប់រូបមានសិទ្ធិ សុំការគាំទ្រ និងដោះស្រាយពីសមាគមបានគ្រប់ពេលវេលា។

**ខ. ភារកិច្ចៈ** សមាជិកគ្រប់រូបមានភារកិច្ចដូចតទៅៈ

- ចូលរួមរាល់សកម្មភាពនានាដែលរៀបចំឡើងដោយសមាគម

- ត្រូវគោរព និងប្រតិបត្តិតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគមដែលគណៈកម្មាធិការប្រតិបត្តិ ឬមហាសន្និបាតសាមញ្ញ ឬ វិសាមញ្ញបានសម្រេច។

## ប្រការ ១០. ការសុំចូលជាសមាជិក

- ការសុំចូលជាសមាជិកសមាគម **ស.អ.ល.ក** ត្រូវបំពេញពាក្យស្នើសុំជាលាយលក្ខណ៍អក្សរតាមគំរូដែលបានរៀបចំដោយសមាគម។

## ប្រការ ១១. ការបាត់បង់សមាជិកភាព

សមាជិកភាពរបស់សមាគមត្រូវបានបាត់បង់ក្នុងករណីៈ

- ទទួលអនិច្ចកម្ម

- ជាប់ពិរុទ្ធដោយមានដីកាសាលពីតុលាការមានសមត្ថកិច្ច

- សុំលាលែងពីសមាជិកសមាគមដោយខ្លួនឯងហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរ

- មិនបានបង់វិភាគទានសមាជិកក្នុងរយៈពេល ១ ឆ្នាំ

- មិនគោរព ឬ រំលោភលើលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់សមាគម ឬ ធ្វើសកម្មភាពសំដៅបំផ្លិចបំផ្លាញសមាគមគ្រប់រូបភាព ហើយត្រូវបានសមាគមសម្រេចឲ្យចេញពីសមាជិកភាព និងត្រូវបានអនុវត្តដោយសំឡេង ៥០ ភាគរយ+១ នៃសមាជិកគណៈកម្មាធិការប្រតិបត្តិ។

# ជំពូកទី ៥

# រចនាសម្ព័ន្ធគ្រប់គ្រង

## ប្រការ ១២. រចនាសម្ព័ន្ធគ្រប់គ្រង

សមាគម **ស.អ.ល.ត** គ្រប់គ្រង និងទទួលខុសត្រូវដោយៈ

- មហាសន្និបាត

- គណៈកម្មាធិការប្រតិបត្តិ

# ផ្នែកទី១

# នីតិវិធីបោះឆ្នោត និងមហាសន្និបាត

## ប្រការ ១៣. មហាសន្និបាត

មហាសន្និបាតជាសម័យប្រជុំកំពូលរបស់សមាគមដែលរៀបចំឡើងដោយគណៈកម្មាធិការប្រតិបត្តិ។ មហាសន្និបាតចែកចេញជា ២ ប្រភេទៈ

ក. មហាសន្និបាតសាមញ្ញៈ ប្រព្រឹត្តទៅរៀងរាល់ ១ ឆ្នាំម្តង ហើយមានភារកិច្ច ៖

- ពិភាក្សា និង អនុម័តលើរបាយការណ៍បូកសរុបការងារកន្លងមកព្រមទាំងលើកទិសដៅការងារសម្រាប់ពេលខាងមុខ។

- ពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

- ពិនិត្យ និងកែសម្រួលលើការកែប្រែលក្ខន្តិកៈរបស់សមាគមក្នុងករណីមានការប្រែប្រួល។

-មហាសន្និបាតអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកស្ថាបនិក និងសមាជិកសកម្មចូលរួមយ៉ាងហោចណាស់ ៥០ភាគរយ+១ ហើយលទ្ធផលអាចយកជាការបានដោយសំឡេងឯកភាពចំនួន ៥០ភាគរយ+១ នៃអង្គសន្និបាត។ លេខាធិការនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើកំណត់ហេតុដាក់ជូនប្រធានគណៈកម្មាធិការពិនិត្យនិងសម្រេច។

- ក្នុងករណីមិនគ្រប់កូរ៉ុម មហាសន្និបាតបន្ទាប់អាចសម្រេចដោយសំឡេង ៥០ភាគរយ+១ នៃវត្តមានសមាជិកចូលរួម។

- ក្នុងករណីសំឡេងស្មើ ប្រធានអង្គសន្និបាតត្រូវមានឧត្តមានុភាពក្នុងការសម្រេច។

-កិច្ចប្រជុំមហាសន្និបាតសាមញ្ញត្រូវផ្ញើជូនដំណឹងមុន ២ សប្តាហ៍យ៉ាងតិចដោយភ្ជាប់មកជាមួយនូវរបៀបវារៈផង។

ខ. មហាសន្និបាតវិសាមញ្ញៈ អាចប្រព្រឹត្តទៅបានយ៉ាងហោចណាស់ក៏ត្រូវមានសមាជិកគណៈកម្មាធិការចំនួន ៥០ភាគរយ+១ ចូលរួមហើយត្រូវផ្ញើជូនដំណឹងមុនយ៉ាងតិច១សប្តាហ៍។ ការអនុម័តលើសេចក្តីសម្រេចរបស់មហាសន្និបាតសាមញ្ញ និងវិសាមញ្ញត្រូវធ្វើឡើងតាមរយៈការលើកដៃ ឬ បោះឆ្នោតជាសំងាត់។

មហាសន្និបាតវិសាមញ្ញមានភារកិច្ច ៖

- ពិនិត្យ ពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈ ក្នុងករណីចាំបាច់
- ពិនិត្យ និងសម្រេចលើការផ្លាស់ប្តូរប្រធានសមាគម
- ពិនិត្យ និងអនុម័តលើការរំលាយសមាគម និងការចាត់ចែងទ្រព្យសម្បត្តិរបស់សមាគម
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលចាំបាច់នៅក្នុងសមាគម ។

# ផ្នែកទី២

# គណៈកម្មាធិការប្រតិបត្តិ

## ប្រការ ១៤. សមាសភាពគណៈកម្មាធិការប្រតិបត្តិ

- គណៈកម្មាធិការប្រតិបត្តិ គឺជាអង្គការប្រតិបត្តិរបស់សមាគម **ស.អ.ល.ភ**។ សមាសភាពគណៈ-កម្មាធិការ ប្រតិបត្តិត្រូវបានជ្រើសរើសឡើងដោយមហាសន្និបាតពេញអង្គរបស់សមាគមហើយមានអាណត្តិ ០៣ ឆ្នាំនិងមាន សិទ្ធិឈរឈ្មោះជាថ្មីត្រឹមតែមួយអាណត្តិទៀតតែប៉ុណ្ណោះ។

- សមាសភាពគណៈកម្មាធិការប្រតិបត្តិនៃសមាគម **ស.អ.ល.ភ** មាន ១២ រូប ក្នុងនោះមានៈ

១. ប្រធាន ០១ រូប

២. អនុប្រធាន ០៥ រូប

៣. អគ្គលេខាធិការ ០១ រូប

៤. ផ្នែកអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ ០១ រូប

៥. ផ្នែកទំនាក់ទំនងជាតិ និងអន្តរជាតិ ០១ រូប

៦. ផ្នែកច្បាប់ ០១ រូប

៧. ផ្នែកហេរញ្ញិក ០១ រូប

៨. លេខាធិការ ០១ រូប។

## ប្រការ ១៥. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ

ក. ប្រធាន:

- ប្រធានគណៈកម្មាធិការប្រតិបត្តិ គឺជាប្រធានសមាគម **ស.អ.ល.ក** ដែលត្រូវមហាសន្និបាតបោះឆ្នោតជ្រើសតាំងដោយសំឡេងភាគច្រើន
- ប្រធានសមាគមទទួលខុសត្រូវដឹកនាំរាល់ការងារទាំងអស់របស់សមាគម
- ទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ការធ្វើឲ្យបាត់បង់ថវិការបស់សមាគម
- មានភារកិច្ចនិងកាតព្វកិច្ចណែនាំ និងអនុវត្តរាល់សេចក្តីសម្រេចរបស់មហាសន្និបាត
- ស្វែងរកផលប្រយោជន៍សមស្របតាមគោលការណ៍របស់សមាគមជូនសមាជិកសមាគម
- ផ្តួចផ្តើមគំនិតដើម្បីធ្វើឲ្យមានភាពប្រសើរឡើង និងទទួលបានជោគជ័យតាមគោលបំណងរបស់សមាគម
- ដឹកនាំ រៀបចំបទបញ្ជាផ្ទៃក្នុងរបស់សមាគម **ស.អ.ល.ក**
- ពិភាក្សា និងអនុម័តលើគម្រោងការងារផ្សេងៗរបស់សមាគម
- ត្រួតពិនិត្យលើរាល់ដំណើរការការងាររបស់សមាគម
- ទទួលខុសត្រូវលើការអនុវត្ត និងលទ្ធផលការងាររបស់សមាគម
- មានភារកិច្ចទំនាក់ទំនងការងារក្នុង និងក្រៅប្រទេសដើម្បីភាពរីកចម្រើនរបស់សមាគម ។

ខ. អនុប្រធាន:

- អនុប្រធានគណៈកម្មាធិការប្រតិបត្តិ គឺជាអនុប្រធានសមាគម **ស.អ.ល.ក** ដែលត្រូវមហាសន្និបាតបោះឆ្នោតជ្រើសតាំងដោយសំឡេងភាគច្រើនបន្ទាប់

- អនុប្រធានសមាគមមានភារកិច្ចជួយប្រធានតាមការប្រគល់សិទ្ធិ

- អនុប្រធានជំនួសប្រធាន ក្នុងពេលដែលប្រធានអវត្តមាន ឬ បាត់បង់សមាជិកភាព ។

គ. អគ្គលេខាធិការ:

- ជាអ្នកគ្រប់គ្រងស្នាក់ការកណ្តាលផ្ទាល់ និងការងាររដ្ឋបាលគ្រប់ផ្នែករបស់សមាគម

- ជាអ្នកថែរក្សាឯកសារទាំងអស់របស់សមាគម លើកលែងតែឯកសារផ្នែកហិរញ្ញវត្ថុ

- ជាអ្នកត្រួតពិនិត្យលើបញ្ជីគណនេយ្យរបស់សមាគម និងចុះហត្ថលេខាលើលិខិតស្នាម និងឯកសារចំណាយផ្សេងៗមុននឹងដាក់ជូនប្រធានពិនិត្យ និងសម្រេច។

ឃ. ផ្នែកអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ:

- រៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលលើវិជ្ជាជីវៈជំនាញដល់សមាជិក

- ទំនាក់ទំនងជាមួយគ្រឹះស្ថានអប់រំក្នុង និងក្រៅប្រទេសដើម្បីជួយដល់សមាជិក

- សិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារលើបច្ចុប្បន្នភាពតម្លៃអចលនវត្ថុនៅទូទាំង ព្រះរាជាណាចក្រកម្ពុជា។

ង. ផ្នែកទំនាក់ទំនងជាតិ និងអន្តរជាតិ:

-ទំនាក់ទំនងទូទៅជាមួយស្ថាប័នរដ្ឋ ឯកជន និងបណ្តាស្ថាប័ន គ្រឹះស្ថានអន្តរជាតិនានាដើម្បីភាពរីកចម្រើន របស់សមាគម និងបង្កើតការយល់ដឹងទូលំទូលាយដល់សាធារណជនជាតិ និងអន្តរជាតិ

-ការងារផ្សេងៗទៀតដែលប្រធានសមាគមប្រគល់ជូន។

ច. ផ្នែកហេរញ្ញិក

- ប្រមូលថវិកាវិភាគទានប្រចាំឆ្នាំរបស់សមាជិក

- គ្រប់គ្រង និងថែរក្សានូវគណនីហិរញ្ញវត្ថុរបស់សមាជិក

- ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ការធ្វើឲ្យបាត់បង់ថវិការបស់សមាគម ។

## ប្រការ ១៦. សិទ្ធិរបស់គណៈកម្មាធិការប្រតិបត្តិ

- ក្នុងករណីមានការផ្លាស់ប្តូរ ឬ រុះរើប្រធាន ឬ អនុប្រធានគណៈកម្មាធិការប្រតិបត្តិត្រូវធ្វើឡើងដោយមហាសន្និបាតពេញអង្គរបស់សមាគម។

# ជំពូកទី ៦

## មូលនិធិសមាគម

**ប្រការ ១៧. មូលនិធិសមាគមបានមកពីៈ**

- វិភាគទាន ភាគទាន និង បរិវិសទាន របស់សមាជិក

- អំណោយរបស់សប្បុរសជនទាំងក្នុង និងក្រៅប្រទេស

- ប្រភពផ្សេងៗទៀតដែលបានមកពីសកម្មភាពស្របច្បាប់របស់សមាគម

- ពល់ប្រាក់វិភាគទានប្រចាំឆ្នាំ ដែលសមាជិកទាំងអស់ត្រូវបង់ ត្រូវធ្វើឡើងក្នុងសប្តាហ៍ ទី ១ នៃខែ មករា រៀងរាល់ឆ្នាំ។

# ជំពូកទី ៧

## ការចាត់ចែង និង ត្រួតពិនិត្យហិរញ្ញវត្ថុ

**ប្រការ ១៨. ការចាត់ចែងហិរញ្ញវត្ថុ**

-ថវិកាទាំងអស់របស់សមាជិកសមាគមត្រូវរក្សាទុកក្នុងគណនីរបស់សមាគមនៅធនាគារណាមួយដែលមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ

-ហេរញ្ញិកសមាគមត្រូវធ្វើការកត់ត្រាចំណូល-ចំណាយឲ្យបានច្បាស់លាស់ដោយមានសក្ខីប័ត្រដើមភ្ជាប់ជាមួយផង

- សិទ្ធិចុះហត្ថលេខាដាក់ និងដកប្រាក់ពីគណនីរបស់សមាគមត្រូវបានប្រគល់ជូនប្រធាន និង ហេរញ្ញិកសមាគម **ស.អ.ល.ក** ។

**ប្រការ ១៩. ការត្រួតពិនិត្យហិរញ្ញវត្ថុ**

- ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវធ្វើដោយសមាជិក ២ នាក់ នៃសមាជិកគណៈកម្មាធិការប្រតិបត្តិដែលត្រូវបានបោះឆ្នោតឲ្យធ្វើជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ នៅរៀងរាល់មហាសន្និបាតសាមញ្ញ និងមានអាណត្តិរយៈពេល ០១ ឆ្នាំ ។

- អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនឹងត្រូវធ្វើការជម្រះបញ្ជីនៅរៀងរាល់ ០១ ឆ្នាំម្តង ហើយដាក់របាយការណ៍នេះ ជូនទៅគណៈកម្មាធិការប្រតិបត្តិដើម្បីពិនិត្យ។

- រាល់ការត្រួតពិនិត្យហិរញ្ញវត្ថុអាចធ្វើទៅបានគ្រប់ពេលវេលា ប្រសិនបើមានការស្នើសុំ ភាគច្រើនពីសមាជិក គណៈកម្មាធិការប្រតិបត្តិ និងមានការឯកភាពពីប្រធានគណៈកម្មាធិការប្រតិបត្តិ។ រៀងរាល់ចុងឆ្នាំហេរញ្ញិកត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុដាក់ជូនមហាសន្និបាតពិនិត្យ និងសម្រេច។ ប៉ុន្តែមុននឹងឆ្លងមហាសន្និបាតត្រូវដាក់ជូន អគ្គលេខាធិការរួចបញ្ជូនមកប្រធានសមាគមពិនិត្យជាមុន។

## ជំពូកទី ៨

## វិសោធនកម្ម

នាយកដ្ឋាន កិច្ចការសមាគម និងគណបក្សនយោបាយ

**ប្រការ ២០.**

លក្ខន្តិកៈនេះអាចកែប្រែបានដោយសំឡេង ៥០ភាគរយ+១ នៃការបោះឆ្នោតនៃសមាជិកដែលមានវត្តមាននៅ មហាសន្និបាតសាមញ្ញដែលរៀបចំឡើងដោយគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ ២១.**

អ្វីដែលមិនមានចែងក្នុងលក្ខន្តិកៈនេះអាចត្រូវបំពេញ និងបញ្ជាក់បន្ថែមក្នុងបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៩

## ការរំលាយសមាគម

**ប្រការ ២២. ការរំលាយសមាគម**

ការរំលាយចោលនូវសមាគមនេះត្រូវមានសំឡេងគាំទ្រ ២/៣ ឡើងទៅតាមរយៈមហាសន្និបាតពេញអង្គ ហើយសំណើសុំរំលាយនេះអាចលើកជូនមហាសន្និបាតពេញអង្គបាន លុះត្រាតែមានសំឡេងគាំទ្រពីសមាជិក គណៈកម្មាធិការប្រតិបត្តិយ៉ាងតិច ២/៣។

**ប្រការ ២៣.**

ក្រោយពេលរំលាយសមាគមទ្រព្យសម្បត្តិរបស់សមាគមត្រូវបានមហាសន្និបាតធ្វើការផ្ទេរដល់សមាគម ឬស្ថាប័ន ឬ អង្គការណាមួយផ្សេងទៀតដែលមានទិសដៅដូចគ្នានឹងសមាគមនេះ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**ប្រការ ២៤.**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៥.**

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ត្រូវធ្វើសកម្មភាពដោយអនុវត្តឲ្យស្របតាមលក្ខន្តិកៈរបស់ខ្លួន ដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ ២៦.**

លក្ខន្តិកៈរបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...06...... ខែ.តុលា.... ឆ្នាំ 2015.

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**ប្រធានសមាគម**

ឧកញ៉ា.លី_ហួរ

**បានតម្កល់ទុកលក្ខន្តិកៈ**

របស់

ស.អ.អ.ល.ក.......................................

ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស

លេខៈ...........ប្រ.ក ចុះថ្ងៃទី.......ខែ.........ឆ្នាំ ២០១៥.។

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ.........ឆ្នាំ ២០១៥.

**នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ**

**ប្រធាន**

ឈឹម កាន